ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តមណ្ឌលគិរី

លេខ០៦៣/១៦...សសរ

# សេចក្តីសម្រេច

## ស្តីពីការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្តមណ្ឌលគិរី ដើម្បីជម្រុញការអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ នៃការអនុវត្តកម្មវិធីជាតិ កំណែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០១៥-២០១៨

ក្រសួងមុខងារសាធារណៈ
រដ្ឋបាល
ចូល
លេខៈ ៤៧០៣
មកដល់ថ្ងៃទី ២១ ខែ ០៧ ឆ្នាំ ១៦
ម៉ោង ៤:៣០

## អភិបាល នៃគណៈអភិបាលខេត្តមណ្ឌលគិរី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការចាត់តាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០២១៦/១៣៧ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការត្រាស់បង្គាប់តែងតាំង អភិបាល នៃគណៈអភិបាលខេត្តមណ្ឌលគិរី
- យោងលិខិតលេខ ១៨៤៦ មស.គករ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្តមណ្ឌលគិរី ដើម្បីជម្រុញការអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ នៃការអនុវត្តកម្មវិធីជាតិ កំណែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០១៥-២០១៨ ដែលមានឈ្មោះដូចខាងក្រោម៖

| | | |
|---|---|---|
| ១.លោក **ចឹង សុចន្ថា** | អភិបាលរងខេត្ត | ជាប្រធាន |
| ២.លោក **ពុច សុរិយា** | ប្រធានមន្ទីរមុខងារសាធារណៈ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣.លោក **ហៀក សុផាន** | នាយករដ្ឋបាលខេត្ត | សមាជិក |
| ៤.លោក **រឿង ឆៃរិទ្ធិ** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ៥.លោកស្រី **ដួច ដារ៉ា** | ប្រធានរតនាគារខេត្ត | សមាជិក |
| ៦.លោក **ឡុង វិបុល** | អភិបាលក្រុងសែនមនោរម្យ | សមាជិក |
| ៧.លោក **មើល សឿន** | អភិបាលស្រុកកោះញែក | សមាជិក |
| ៨.លោក **នួន សារ៉ន** | អភិបាលស្រុកពេជ្រាដា | សមាជិក |
| ៩.លោក **នង ឧត្តរារី** | អភិបាលស្រុកអូររាំង | សមាជិក |
| ១០.លោក **ស៊ិន វណ្ណឧត្តម** | អភិបាលស្រុកកែវសីមា | សមាជិក |
| ១១.លោក **ឌី ផល្លា** | អនុប្រធានមន្ទីរមុខងារសាធារណៈខេត្ត | ជាមន្ត្រីបង្គោល |
| ១២.លោកស្រី **គូ ចន្ថា** | មន្ត្រីនៃមន្ទីរមុខងារសាធារណៈ ខេត្ត | ជាមន្ត្រីបង្គោល |

**ប្រការ២.-**

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈខេត្តមណ្ឌលគិរី មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខប្រធានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រង និងដឹកនាំគ្រប់ការងារពាក់ព័ន្ធទៅនឹងកម្មវិធី យុទ្ធសាស្ត្រ និងសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- សម្របសម្រួលការងារកែទម្រង់រដ្ឋបាលសាធារណៈរវាងក្រសួងស្ថាប័នសាមីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាមួយលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- សម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពការងារកែទម្រង់រដ្ឋបាលសាធារណៈ
- ត្រូវរៀបចំផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងធ្វើរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈជូនប្រធានស្ថាប័នសាមីជាប្រចាំ
- ត្រូវរាយការណ៍អំពីវឌ្ឍនភាពឱ្យបានទៀងទាត់រៀងរាល់ត្រីមាសមកលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈក្នុងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ
- ក្រុមការងារ ត្រូវផ្តល់កិច្ចសហការ និងសម្របសម្រួលជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈតាមរយៈមន្ត្រីបង្គោលក្នុងការស្វែងរក និងប្រមូលព័ត៌មាន ការរៀបចំផែនការសកម្មភាព ការអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ការរៀបចំរបាយការណ៍ និងបញ្ជូនរបាយការណ៍សង្ខេបនូវសូចនាករដែលទាក់ទងទៅនឹងវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈរបស់សាមីក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមមកលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈឬនាយកដ្ឋានជំនាញនៃក្រសួងមុខងារសាធារណៈ។ ជាពិសេស មន្ត្រីបង្គោល ត្រូវចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធតាមដាន ត្រួតពិនិត្យនិងវាយតម្លៃសម្រាប់ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ។

**ប្រការ៣.-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៤.-**

នាយករដ្ឋបាលខេត្ត លោកអភិបាលក្រុង ស្រុកទាំងប្រាំ មន្ទីរ/អង្គភាពជុំវិញខេត្ត និងសាមីខ្លួនដូចក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

មណ្ឌលគិរី, ថ្ងៃទី១៥.... ខែ.ឧសភា.. ឆ្នាំ២០១៦

**អភិបាល**

ស្វាយ_សំអ៊ាង

**ចម្លងជូន៖**

- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ
- ក្រុមប្រឹក្សាខេត្ត
  (ដើម្បីជូនជ្រាប)
- ដូចប្រការ៤
  (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ